## សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ

## សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ សង្កាត់

*ក្រោមក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TSSD)*

*Loan/Grants No. 2599/0186-CAM Tonle Sap Poverty Reduction and Smallholder Development Project*

| | | |
|---|---|---|
| ខេត្ត ៖ សៀមរាប | ក្រុង ៖ សៀមរាប | សង្កាត់ ៖ សាលាកំរើក |

ការពិពណ៌នាអំពីលទ្ធផលកិច្ចសន្យា ៖ ស្តារប្រឡាយស្រោចស្រពប្រវែង១៨៤០ម៉ែត្រនិងសាងសង់ប្រពន្ធ័លូរំដោះទឹក ប្រវែង៤០០ម៉ែត្រចំនួន០១កន្លែង។

រយៈពេលថែទាំ ៖ រយៈពេល០៦ខែ

| | |
|---|---|
| តម្លៃប៉ាន់ស្មាន | USD ៣០,៥៦៣ ដុល្លារ (សាមសិបពាន់ប្រាំរយហុកសិបបីដុល្លារគត់) |
| អ្នកដែលអាចដេញថ្លៃ | អ្នកទទួលការប្រភេទទី១ និង២ |
| ប្រាក់កក់ធានាការដេញថ្លៃ | យ៉ាងតិច USD ៦១២ (ប្រាំមួយរយដប់ពីរដុល្លារគត់) |
| ឈ្មោះធនាគារពាណិជ្ជដែលត្រូវតម្កល់ប្រាក់កក់ | ធនាគារពាណិជ្ជណាមួយ |
| រយៈពេលសុពលភាពនៃសំណើដេញថ្លៃ | ចំនួន៤៥(សែសិបប្រាំ)ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ |
| ទីកន្លែងដែលអាចទទួលឯកសារដេញថ្លៃ | សង្កាត់សាលាកំរើក ឬនៅទីចាត់ការផែនការនិងវិនិយោគខេត្ត |
| ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ | សាលាសង្កាត់ សាលាកំរើក |
| កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ | ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ |
| • ពេលវេលាចាប់ផ្តើមទទួលសំណើដេញថ្លៃ | ម៉ោង ០៩.០០ ព្រឹក |
| • ពេលវេលាឈប់ទទួលសំណើដេញថ្លៃ | ម៉ោង ០៩.១០ ព្រឹក |
| • ពេលវេលាបើកសំណើដេញថ្លៃ | ម៉ោង ០៩.១០ ព្រឹក |

**កំណត់សម្គាល់ ÷**

- ឯកសារដេញថ្លៃត្រូវភ្ជាប់មកជាមួយនូវប័ណ្ណធានាការដេញដោយប្រើទម្រង់ធានាការដេញថ្លៃ( ទម្រង់លិខិតធានារបស់ធនាគារ )ដូចមានភ្ជាប់នៅក្នុងឯកសារដេញថ្លៃនេះ ដោយមានទឹកប្រាក់កក់ធានាដូចបានកំណត់ខាងលើ។
- ក្នុងរយៈពេល១៤ថ្ងៃបន្ទាប់ពីទទួលបានដំណឹងផ្តល់កិច្ចសន្យាអ្នកដេញថ្លៃឈ្នះត្រូវផ្តល់ប្រាក់កក់ធានាការអនុវត្តក្នុងទម្រង់ជាប័ណ្ណធានារបស់ធនាគារចំនួន១០ភាគរយនៃតម្លៃកិច្ចសន្យា។ការបរាជ័យក្នុងការអនុវត្តចំនុចខាងលើនេះគឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់លប់ចោលនៃការផ្តល់កិច្ចសន្យា និងរឹបអូសប្រាក់ប្រាក់កក់ធានាការដេញថ្លៃ។ការធានាការអនុវត្តត្រូវមានសុពលភាពរហូតដល់រយៈពេល ៣០ ថ្ងៃ បន្ទាប់ពីចេញរបាយការណ៍បញ្ចប់ការងារ ១០០ភាគរយ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយ។ ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នា ឬពាក់ព័ន្ធក្នុងការក្លែងបន្លំ ឬអំពើពុករលួយជាមួយអ្នកទទួលការដទៃ អ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយ ប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។

ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១៦

**ចៅសង្កាត់**

សោម ឡូន

**សំណើដេញថ្លៃ**

**សម្រាប់កិច្ចសន្យាការងារសាងសង់របស់ក្រុមប្រឹក្សាឃុំ សង្កាត់**

*ក្រោមក្របខ័ណ្ឌគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (TSSD)*

*Loan/Grants No. 2599/0186-CAM Tonle Sap Poverty Reduction and Smallholder Development Project*

| ខេត្ត ៖ សៀមរាប | ក្រុង ៖ សៀមរាប | សង្កាត់៖ សាលាកំរើក |
|---|---|---|
| ឈ្មោះគម្រោង៖ ស្តារប្រឡាយស្រោចស្រពប្រវែង១៨៤០ម៉ែត្រនិងសាងសង់ប្រពន្ធ័លូរំដោះទឹកប្រវែង៤០០ម៉ែត្រ ចំនួន០១កន្លែង។ | | |
| ឈ្មោះអ្នកដេញថ្លៃ ៖ | ឈ្មោះក្រុមហ៊ុន ៖ | លេខអត្តសញ្ញាណប័ណ្ណ ៖ |

| ល.រ | ការពិពណ៌នា | ភូមិ | បរិមាណ | ឯកតា | តម្លៃឯកតា(ដុល្លារ) | តម្លៃសរុប (ដុល្លារ) |
|---|---|---|---|---|---|---|
| ១ | ស្តារប្រឡាយស្រោចស្រព | វត្តស្វាយ | *១.៨៤០* | គម | | |
| ២ | ប្រពន្ធ័លូរំដោះទឹកប្រវែង ៤០០ម៉ែត្រ | វត្តស្វាយ | ០១ | កន្លែង | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| **សរុបតម្លៃដាក់ដេញ** | | | | | | |
| (តម្លៃដាក់ដេញសរុបជាអក្សរ..................................................................................................)។ | | | | | | |

- ខ្ញុំជាអ្នកដេញថ្លៃបានអាន និងយល់ច្បាស់អំពីកិច្ចសន្យា គំនូសប្លង់ និងសេចក្តីលម្អិតបច្ចេកទេស។ ខ្ញុំបានយល់ព្រមសាងសង់ទៅតាមកិច្ចសន្យាពេលវេលាដែលបានកំណត់និងជួសជុលថែទាំលទ្ធផលកិច្ចសន្យាឱ្យស្ថិតនៅក្នុងល័ក្ខខ័ណ្ឌល្អក្នុងរយៈពេល៦ខែបន្ទាប់ពីសាងសង់រួចជាស្ថាពរ។
- អ្នកទទួលការត្រូវចូលរួមដេញថ្លៃប្រកបដោយការប្រកួតប្រជែង ដោយគ្មានឃុបឃិតស៊ុមគ្រលំគ្នា និងមិនពាក់ព័ន្ធនឹងការក្លែងបន្លំឬអំពើពុករលួយ។ប្រសិនបើអ្នកទទួលការណាឃុបឃិតស៊ុមគ្រលំគ្នាឬពាក់ព័ន្ធក្នុងការក្លែងបន្លំឬអំពើពុករលួយជាមួយអ្នកទទួលការដទៃអ្នកទទួលការទាំងនោះនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត និងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា ហើយប្រាក់កក់ធានាការដេញថ្លៃរបស់អ្នកដេញថ្លៃទាំងនោះនឹងត្រូវបានរឹបអូសផ្ទេរបង្វែរបង់ចូលថវិការដ្ឋ។
- កំហុសមួយចំនួនអាចត្រូវបានកែតម្រូវដោយគណៈកម្មការលទ្ធកម្ម។ ប្រសិនបើអ្នកដេញថ្លៃមិនទទួលយកការកែតម្រូវនេះទេ គណៈកម្មការលទ្ធកម្មនឹងបដិសេធសំណើដេញថ្លៃនេះ ដោយចាត់ទុកថា ជាសំណើដេញថ្លៃដែលមិនមានសុពលភាព។

**កំណត់សម្គាល់ ៖** សំណើដេញថ្លៃនេះមានសុពលភាពរយៈពេល**៤៥ថ្ងៃ** ចាប់ពីកាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ។

ថ្ងៃទី....... ខែ........... ឆ្នាំ........

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

## លទ្ធផល និង តម្លៃប៉ាន់ស្មានគម្រោងហេដ្ឋារចនាសម្ព័ន្ធ

| ខេត្ត :សៀមរាប | ក្រុង : សៀមរាប | សង្កាត់: សាលាកំរើក | ឈ្មោះគម្រោង : ស្ពានប្រឡាយស្រោចស្រពប្រវែង១៩៤០ម៉ែត្រនិងសាងសង់ ប្រពន្ធ័លូរំដោះទឹកប្រវែង៤០០ម៉ែត្រ។ |
|---|---|---|---|

| ល.រ | ឈ្មោះភូមិ | លេខ លទ្ធផល | ការពិពណ៌នាអំពីលទ្ធផល | ថ្មី ឬជួសជុល កែលំអរ | តាមប្លង់គជវវ (បាទ ឬ ទេ) | បរិមាណ | ឯកត្តា | ស្តង់ដារទំហំទី១ | | ស្តង់ដារទំហំទី២ | | តំលៃ ជាដុល្លារ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ប្រភេទ | ទំហំ | ប្រភេទ | ទំហំ | ឯកត្តា | សរុប |
| ១ | វត្តស្វាយ | 1020101 | ប្រឡាយ | ថ្មី | បាទ | 1.44 | គម | ជំរៅ | 1.5m | ទទឹង | 3m | | |
| ២ | វត្តស្វាយ | 540 | លូរំដោះទឹក | ថ្មី | បាទ | 1 | កន្លែង | អង្កត់ផ្ចិត | 0.8 m | ប្រវែង | 400m | | |
| | | | | | | | | | | | | | |
| **តំលៃសរុបកិច្ចសន្យា** | | | | | | | | | | | | | |

**ថ្ងៃទី ខែ ឆ្នាំ ២០១៦** **ថ្ងៃទី ខែ ឆ្នាំ ២០១៦**

**ចៅសង្កាត់** **អ្នកជំនួយបច្ចេកទេស**

ទម្រង់ទី៣៩

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសស្តីពី
# ក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ

ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញសូមប្រកាសអះអាងដូចខាងក្រោម ÷

១. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានទំនាក់ទំនងណាមួយដែលជាទំនាស់ផលប្រយោជន៍ដែលបានចែងនៅក្នុងឯកសារដេញថ្លៃ។

២. បើយើងខ្ញុំបានដឹងអំពីទំនាស់ផលប្រយោជន៍ទាំងនេះ យើងខ្ញុំនឹងរាយការណ៍ភ្លាមជូនទៅគណៈកម្មការលទ្ធកម្ម ឃុំ សង្កាត់ អភិបាលរាជធានី ខេត្ត និងក្រុមការងារគណនេយ្យភាពរាជធានី ខេត្ត។

៣. ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ បង្គាប់បញ្ជា និងឃុបឃិតស៊ីគ្រលំចំពោះការដាក់សំណើដេញថ្លៃរបស់ខ្ញុំឡើយ។

៤. យើងខ្ញុំបានដឹងច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវអនុញ្ញាតឱ្យរដ្ឋាភិបាល និងឬទីភ្នាក់ងារផ្តល់មូលនិធិ ធ្វើការត្រួតពិនិត្យនូវរាល់ឯកសារនានាដែលទាក់ទងនឹងការរៀបចំសំណើដេញថ្លៃរបស់យើងខ្ញុំ និងកិច្ចសន្យាណាមួយដែលអាចជាលទ្ធផលពីភាពមិនប្រក្រតីដែលគិតស្មានមិនដល់ ទោះបីជាកិច្ចសន្យានោះយើងខ្ញុំឈ្នះ ឬចាញ់ក៏ដោយ។

៥. នៅក្នុងដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្ម និងកិច្ចសន្យាណាមួយដែលឈ្នះក្នុងការដេញថ្លៃនេះ ខ្ញុំ បុគ្គលិករបស់ខ្ញុំ ទីប្រឹក្សារបស់ខ្ញុំ អ្នកសហការ/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ម្ចាស់ភាគហ៊ុនរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ព្រមទាំងអ្នកសហការ និងសាច់ញាតិរបស់ពួកគេ នឹងមិនមានចំណាយប្រាក់ ឬផ្តល់ជូនជាសារគុណឱ្យទៅបុគ្គលិក ទីប្រឹក្សា អ្នកសហការ ឬសាច់ញាតិនៃអ្នកដែលពាក់ព័ន្ធនៅក្នុងដំណើរការលទ្ធកម្ម ការអនុវត្តគម្រោង និងការចេញអាណត្តិទូទាត់។

ក្នុងករណីមិនគោរពតាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ខ្ញុំជាអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ នឹងមិនត្រូវបានអនុញ្ញាតឱ្យដាក់សំណើដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេសកម្ពុជា។

ថ្ងៃទី...... ខែ......... ឆ្នាំ......

**ហត្ថលេខា និងឈ្មោះអ្នកដេញថ្លៃ**

ទម្រង់លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**ធនាគារ.............**

លេខ..................

## លិខិតធានាប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**

**លោក លោកស្រីមេឃុំ ចៅសង្កាត់................**

ដោយហេតុថាក្រុមហ៊ុន.................... មានបំណងដាក់ពាក្យសុំដេញថ្លៃ កិច្ចសន្យា.......................... របស់ឃុំ សង្កាត់...................... ដែលនឹងត្រូវប្រជុំបើកសំណើដេញថ្លៃនៅថ្ងៃទី....... ខែ.......... ឆ្នាំ.......... តាមសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់កិច្ចសន្យារបស់ក្រុមប្រឹក្សាឃុំ សង្កាត់...................... ចុះថ្ងៃទី....... ខែ............ ឆ្នាំ.........។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះលោក លោកស្រីមេឃុំ ចៅសង្កាត់................. នូវប្រាក់កក់ធានាការដេញថ្លៃចំនួន................................ (ជាអក្សរ...............................................................)។

ក្នុងករណីមានល័ក្ខខ័ណ្ឌណាមួយកើតមានឡើងក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីខាងក្រោម ៖

1. ប្រសិនបើអ្នកដេញថ្លៃដកពាក្យរបស់ខ្លួនក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
2. ប្រសិនបើអ្នកដេញថ្លៃមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ
3. ប្រសិនបើអ្នកដេញថ្លៃមិនព្រមកក់ប្រាក់ធានាការអនុវត្ត។

នោះធនាគារយើងខ្ញុំនឹងធ្វើការផ្ទេរបង្វែរចូលថវិការជូននូវចំនួនប្រាក់ខាងលើ នៅពេលដែលបានទទួលពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សរពីលោក លោកស្រីមេឃុំ ចៅសង្កាត់.............................។

លិខិតធានានេះនឹងផុតកំណត់៖ ក). ប្រសិនបើអ្នកដេញថ្លៃគឺជាអ្នកដេញថ្លៃឈ្នះទទួលបានការបញ្ជាក់ថាបានចុះកិច្ចសន្យាដោយអ្នកដេញថ្លៃ និងបានចេញលិខិតធានាការអនុវត្ត ខ). ប្រសិនបើអ្នកដេញថ្លៃមិនបានជោគជ័យ (១)បង្ហាញឯកសារច្បាប់ចតចម្លងនៃកិច្ចសន្យារបស់អ្នកដេញថ្លៃឈ្នះ ឬ (២) រយៈពេល៣០ថ្ងៃ បន្ទាប់ពីផុតកំណត់នៃសុពលភាពដេញថ្លៃ ។

ធ្វើនៅ................. ថ្ងៃទី....... ខែ............ ឆ្នាំ.........

**នាយកធនាគារ**

ទម្រង់លិខិតធានាប្រាក់កក់ធានាការអនុវត្ត

**ធនាគារ.............**

លេខ..................

**លិខិតធានាប្រាក់កក់ធានាការអនុវត្ត**

**សូមគោរពជូន**

**លោក លោកស្រីមេឃុំ ចៅសង្កាត់............**

ដោយហេតុថាក្រុមហ៊ុន..................... បានទទួលលិខិតលេខ........... ចុះថ្ងៃទី....... ខែ........... ឆ្នាំ......... របស់ឃុំ សង្កាត់.......................... ស្តីពីការសម្រេចផ្តល់កិច្ចសន្យា................................ ក្នុងតម្លៃកិច្ចសន្យាចំនួន........................... (ជាអក្សរ....................................................)។

ក្នុងលិខិតសម្រេចផ្តល់កិច្ចសន្យា ឃុំ សង្កាត់បានកំណត់ឱ្យក្រុមហ៊ុនតម្កល់ប្រាក់កក់ធានាការអនុវត្តចំនួន ...................... (ជាអក្សរ.............................................) ក្នុងទម្រង់ជា**លិខិតធានាប្រាក់កក់ធានាការអនុវត្ត** ដែលចេញដោយធនាគារ.......................... ដើម្បីធានាការអនុវត្តកាតព្វកិច្ច ស្របតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។

យើងខ្ញុំសូមធានា និងទទួលខុសត្រូវចំពោះលោក លោកស្រីមេឃុំ ចៅសង្កាត់................. នូវប្រាក់កក់ធានាការអនុវត្តចំនួន........................... (ជាអក្សរ......................................................)។

ប្រាក់កក់ខាងលើនេះនឹងផ្ទេរបង្វែរចូលថវិការដ្ឋ នៅពេលមានពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សររបស់លោក លោកស្រីមេឃុំ ចៅសង្កាត់.................... ដែលបញ្ជាក់ថា អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញមិនគោរពតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន.......................... គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ។

លិខិតធានានេះមានសុពលភាពរហូតរយៈពេល៣០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍បញ្ចប់ការងារ១០០ភាគរយ ។

ធ្វើនៅ................. ថ្ងៃទី....... ខែ............ ឆ្នាំ.........

**នាយកធនាគារ**